មជ្ឈមណ្ឌលកម្ពុជា 4.0
CAMBODIA 4.0 CENTER
Inspire Empower Succeed

**Article 67**

# Information Disorder

ការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ថ្នាលបណ្ដាញសង្គម និងបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត បាននិងកំពុងផ្លាស់ប្ដូររបៀបដែលព័ត៌មានត្រូវបានបង្កើត, ចែករំលែក និងប្រើប្រាស់។ ទោះបីជាការវិវត្តនៃបច្ចេកវិទ្យា បានធ្វើឱ្យការទទួលបានព័ត៌មានកាន់តែមានវិសាលភាពទូលំទូលាយក៏ដោយ ប៉ុន្តែក៏បានបង្កើតជាបរិយាកាសអំណោយផលដល់ការបង្កើត និងចែកចាយព័ត៌មានក្នុងទម្រង់ Information Disorder ផងដែរ។ ការរីករាលដាលនៃព័ត៌មានបែបនេះ មិនមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែត្រូវបានជំរុញដោយកត្តាសំខាន់ៗ ដូចជា ដើម្បីផលប្រយោជន៍ផ្នែកនយោបាយ, ហិរញ្ញវត្ថុ ឬដើម្បីបង្កអសន្តិសុខនៅសង្គមជាដើម។ យោងតាមអ្នកស្រាវជ្រាវផ្នែកប្រព័ន្ធផ្សព្វផ្សាយ លោកស្រី Claire Wardle និងលោក Hossein Derakhshan ពាក្យ Information Disorder នេះត្រូវបានប្រើប្រាស់ ដើម្បីពណ៌នាអំពីប្រភេទព័ត៌មានទាំងបី រួមមាន Disinformation, Misinformation, និង Malinformation។ Disinformation គឺជាខ្លឹមសារដែលត្រូវបានបង្កើតឡើង និងផ្សព្វផ្សាយដោយចេតនា ក្នុងគោលបំណងបង្កឱ្យមានការយល់ច្រលំ, បង្ខូចកេរ្តិ៍ឈ្មោះ ឬបង្កគ្រោះថ្នាក់។ ចំណែកឯ Misinformation ក៏សំដៅដល់ខ្លឹមសារព័ត៌មានមិនពិត ប៉ុន្តែការចែករំលែកធ្វើឡើងដោយអចេតនា ដោយអ្នកចែករំលែកមិនបានដឹងថាព័ត៌មាននោះជារឿងមិនពិត ឬបំភ័ន្តឡើយ ប៉ុន្តែផ្ទុយទៅវិញ ពួកគេគិតថាជាការជួយ ឬផ្ដល់ព័ត៌មានទៅវិញ។ ដោយឡែក Malinformation គឺជាព័ត៌មានដែលផ្អែកលើការពិត ដែលមិនគួរផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែត្រូវបានគេយកមកទម្លាយ ឬផ្សព្វផ្សាយក្នុងចេតនាមិនល្អ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ, សេចក្ដីថ្លៃថ្នូរ, ឯកជនភាព ឬបង្ខូចកេរ្តិ៍ឈ្មោះបុគ្គលណាម្នាក់។ ដំណើរការនៃការផ្សព្វផ្សាយព័ត៌មានបែបនេះ តែងតែឆ្លងកាត់ដំណាក់កាលស្នូលចំនួនបី គឺចាប់ផ្ដើមពីការបង្កើតមាតិកា ដែលមានគោលបំណងបង្កបញ្ហា, ឈានទៅដល់ការផលិត ដោយកែច្នៃឱ្យមានភាពទាក់ទាញ តាមរយៈរូបភាព, វីដេអូ ឬចំណងជើង ដើម្បីទាក់ទាញការចាប់អារម្មណ៍ និងចុងក្រោយគឺការចែកចាយលើថ្នាលបណ្ដាញសង្គម។ លំហូរនៃព័ត៌មានទាំងនេះ ត្រូវបានជំរុញបន្ថែមដោយប្រព័ន្ធ Algorithms នៃថ្នាលបណ្ដាញសង្គម ដែលផ្ដោតលើការបង្កើនអន្តរកម្ម និងទាក់ទាញការចូលមើលពីអ្នកប្រើប្រាស់។ កត្តានេះបានធ្វើឱ្យទំហំនៃផលប៉ះពាល់កាន់តែមានភាពស្រួចស្រាល់ឡើង ស្របពេលដែលចិត្តវិទ្យារបស់មនុស្សមាននិន្នាការស្រូបយក និងជឿជាក់លើព័ត៌មានណាដែលស្របនឹងទស្សនៈ ឬការយល់ឃើញផ្ទាល់ខ្លួនដែលមានស្រាប់ (Confirmation Bias)។ ទន្ទឹមនឹងនេះ ការវិវត្តនៃ AI ក៏កំពុងជំរុញឱ្យការបង្កើត និងចែកចាយរូបភាព ឬវីដេអូ Deepfakes អាចប្រព្រឹត្តទៅបានកាន់តែរហ័ស និងកាន់តែមានហានិភ័យខ្ពស់ផងដែរ។ មាតិកាទាំងនេះនឹងងាយរីករាលដាលយ៉ាង

ទូលំទូលាយ ជាពិសេសក្នុងស្ថានភាពព័ត៌មានទាន់ហេតុការណ៍ ឬនៅក្នុងតំបន់ដែលខ្វះខាតប្រភពព័ត៌មានផ្លូវការ ដែលងាយធ្វើឱ្យសាធារណជនរងឥទ្ធិពល និងការខាតបង់ពីការយល់ច្រឡំ។ ជារួម យុទ្ធសាស្ត្របំភ័ន្តដ៏ទំនើបទាំងនេះ មិនត្រឹមតែបង្កើតភាពវឹកវរក្នុងបណ្តាញសង្គមព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែបាននិងកំពុងជះឥទ្ធិពលយ៉ាងជ្រាលជ្រៅ និងបង្កជាហានិភ័យដ៏ធំធេងដល់ស្ថិរភាពសង្គម សន្តិសុខជាតិ និងដំណើរការលទ្ធិប្រជាធិបតេយ្យ ដែលជាប្រធានបទស្នូលដែលនឹងត្រូវធ្វើការវិភាគឱ្យកាន់តែស៊ីជម្រៅ។

## I. វត្តមាននៃ Information Disorder

ការវិវត្តនៃបច្ចេកវិទ្យាបានផ្លាស់ប្តូរទម្រង់នៃការចែករំលែកព័ត៌មានយ៉ាងខ្លាំង ចាប់តាំងពីការផ្សព្វផ្សាយពីមាត់មួយទៅមាត់មួយ, ការបោះពុម្ពផ្សាយតាមវិទ្យុ ទូរទស្សន៍ រហូតដល់ការផ្សព្វផ្សាយតាមអ៊ីនធឺណិត និងបណ្តាញសង្គម។ បច្ចេកវិទ្យាទាំងនេះបានបង្កើនល្បឿន និងភាពងាយស្រួលក្នុងការបង្កើត ក៏ដូចជាចែកចាយព័ត៌មានយ៉ាងរហ័ស។ វត្តមាននៃ Information Disorder មិនមែនជារឿងថ្មីនោះទេ ព្រោះព័ត៌មានបែបនេះមានវត្តមានតាំងពីសម័យបុរាណមកម្ល៉េះ។

- **សម័យរ៉ូមបុរាណ ក្នុងសតវត្សរ៍ទី១ មុនគ.ស.៖** អ្នកប្រវត្តិសាស្ត្របានកត់ត្រាអំពីសង្គ្រាមព័ត៌មានរវាងឥស្សរជនដ៏មានឥទ្ធិពលនៅសម័យនោះ លោក Octavian អ្នកស្នងមរតករបស់លោក Julius Caesar និងគូប្រជែងរបស់គាត់គឺលោក Mark Antony។ ភាគីទាំងពីរបានប្រើប្រាស់កាក់ កំណាព្យ ខិត្តប័ណ្ណ និងសុន្ទរកថា ដើម្បីទាក់ទាញការគាំទ្រពីសាធារណជន និងយោធា។ លោក Octavian បានអានលិខិតបណ្តាំរបស់ Antony ឮៗនៅក្នុងព្រឹទ្ធសភារ៉ូម ដែលខ្លឹមសារនោះបង្ហាញថា Antony មានភក្តីភាពចំពោះម្ចាស់ក្សត្រី Cleopatra នៃប្រទេសអេហ្ស៊ីប ជាងប្រជាជនរ៉ូម។ បើទោះបីជាអ្នកប្រវត្តិសាស្ត្រនៅតែជជែកវែកញែកថាតើលិខិតនោះជាការពិតដែលគេទម្លាយក្នុងបំណងអាក្រក់ (Malinformation) ឬជាការប្រឌិតឡើងទាំងស្រុង (Disinformation) ក៏ដោយ ប៉ុន្តែការផ្សព្វផ្សាយនោះបានជួយឱ្យ Octavian ទទួលបានការគាំទ្រ និងក្លាយជាអ្នកគ្រប់គ្រងផ្តាច់មុខនៃអាណាចក្ររ៉ូមនៅទីបំផុត។
- **ព័ត៌មានមិនពិតអំពីជំងឺរាតត្បាត នៅសតវត្សរ៍ទី១៧៖** អំឡុងពេលមានការឆ្លងរាលដាលនៃជំងឺប៉េស្ត (Plague) នៅសតវត្សរ៍ទី១៧ ទីក្រុងមួយចំនួនក្នុងប្រទេសអ៊ីតាលីបានរាយការណ៍ខុស ឬលាក់បាំងចំនួនអ្នកឆ្លង ដើម្បីចៀសវាងការដាក់ឱ្យនៅដាច់ដោយឡែក និងដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ច-សង្គម។ លើសពីនេះ ការបំភ្លៃព័ត៌មាន និងពាក្យចចាមអារ៉ាមអំពីជំងឺនេះក៏ត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយ ដើម្បីកេងចំណេញពីដៃគូប្រជែងផងដែរ។
- **ការប្រឌិតអំពី "The Great Moon Hoax" ក្នុងសតវត្សរ៍ទី១៩៖** នៅឆ្នាំ១៨៣៥ កាសែត The Sun របស់ទីក្រុងញូវយ៉ក បានបង្កើតព្រឹត្តិការណ៍ដ៏ល្បីល្បាញមួយហៅថា "The Great Moon Hoax" ដោយបានបោះពុម្ពផ្សាយអត្ថបទប្រឌិតអំពីការរកឃើញជីវិតនៅលើព្រះច័ន្ទ ដូចជា មនុស្សមានស្លាបប្រចៀវ, សត្វ Unicorn និងសត្វចម្លែកៗដទៃទៀត។ ការប្រឌិតនេះធ្វើឡើងក្នុងគោលបំណង

បង្កើនការលក់ និងទាក់ទាញអ្នកអាន ដែលធ្វើឱ្យកាសែតនេះក្លាយជាកាសែតដែលមានអ្នកអានច្រើនបំផុតមួយនៅអាមេរិកនាពេលនោះ។

◉ **ការឃោសនាសម័យសង្គ្រាមនៅអូស្ត្រាលី ក្នុងសតវត្សរ៍ទី២០៖** អំឡុងសង្គ្រាមលោកលើកទីមួយ ឆ្នាំ១៩១៦ និង ១៩១៧ រដ្ឋាភិបាលអូស្ត្រាលីបានរៀបចំប្រជាមតិ (Referendum) ដើម្បីសួរមតិប្រជាជនលើការបង្ខំឱ្យបុរសចុះឈ្មោះចូលបម្រើកងទ័ពនៅក្រៅប្រទេស។ ក្នុងយុទ្ធនាការនោះ គណបក្សនយោបាយនានាបានផលិតផ្ទាំងរូបភាពឃោសនា (ទាំងយុទ្ធនាការគាំទ្រ និងប្រឆាំង) ដោយប្រើប្រាស់អារម្មណ៍, ភាពភ័យខ្លាច និងស្មារតីស្នេហាជាតិ ដើម្បីជះឥទ្ធិពលលើការសម្រេចចិត្តរបស់ម្ចាស់ឆ្នោត ដែលជាឧទាហរណ៍ច្បាស់លាស់នៃការប្រើប្រាស់ឃោសនានយោបាយ។

◉ **ទ្រឹស្តីឃុបឃិតជុំវិញការធ្វើឃាតលោក John F. Kennedy ក្នុងសតវត្សរ៍ទី២០៖** ក្រោយការធ្វើឃាតលោកប្រធានាធិបតីអាមេរិក John F. Kennedy ក្នុងឆ្នាំ១៩៦៣ ទ្រឹស្តីឃុបឃិតជាច្រើនបានផ្ទុះឡើង និងរីករាលដាលយ៉ាងរហ័ស ដោយបានទម្លាក់កំហុសលើភ្នាក់ងារសម្ងាត់ CIA, រដ្ឋាភិបាលបរទេស ឬក្រុម Mafia។ សៀវភៅ, ឯកសារ និងគេហទំព័ររាប់មិនអស់ត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយទ្រឹស្តីទាំងនេះ ទោះបីជាគ្មានភស្តុតាងច្បាស់លាស់ក៏ដោយ។

◉ **រូបភាពសាច់ក្រក Chorizo លើលំហអាកាស ក្នុងសតវត្សរ៍ទី២១៖** នៅឆ្នាំ២០២២ អ្នកវិទ្យាសាស្ត្រជនជាតិបារាំងម្នាក់បានបង្ហោះរូបភាពមួយសន្លឹកលើបណ្តាញសង្គម ដោយអះអាងថាជារូបភាពផ្កាយមួយ ដែលថតដោយ James Webb Space Telescope។ ប៉ុន្តែក្រោយមក លោកបានទម្លាយថា វាគ្រាន់តែជាសាច់ក្រកហឹរបែបអឺរ៉ុប (Chorizo) មួយចំណិតប៉ុណ្ណោះ។ ការបង្ហោះនេះធ្វើឡើងក្នុងន័យកំប្លែង និងដើម្បីដាស់តឿនមនុស្សគ្រប់គ្នាឱ្យចេះរិះគិត និងផ្ទៀងផ្ទាត់ព័ត៌មាន ទោះបីជាចេញពីប្រភពដែលគួរឱ្យទុកចិត្តក៏ដោយ។ នេះជាឧទាហរណ៍នៃ «ព័ត៌មានបំភ័ន្តដែលមានបំណងល្អ» (Well-intended Disinformation/Satire)។

ដូច្នេះ ទាំងអស់នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា Information Disorder តែងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការបំភ័ន្តការយល់ឃើញ និងជំនឿរបស់មនុស្សនៅក្នុងសង្គម។ នៅក្នុងសម័យឌីជីថលបច្ចុប្បន្ន បណ្តាញផ្សព្វផ្សាយសង្គមបានក្លាយជាកាតាលីករធ្វើឱ្យព័ត៌មានទាំងនេះរីករាលដាលលឿន និងមានឥទ្ធិពលជាងពេលណាៗទាំងអស់។

## II. ផលប៉ះពាល់នៃ Information Disorder

នាពេលបច្ចុប្បន្ន ថ្នាលបណ្តាញសង្គម ក៏ដូចជាបច្ចេកវិទ្យាឌីជីថលនានា បានផ្តល់ឱកាសឱ្យមនុស្សគ្រប់រូបអាចចូលរួមផ្សព្វផ្សាយ និងចែកចាយព័ត៌មានដោយសេរី ប៉ុន្តែដោយសារការចែករំលែកព័ត៌មានមានភាពរហ័សពេក បានធ្វើឱ្យសាធារណជនពិបាកក្នុងការកត់សម្គាល់ភាពខុសគ្នារវាងអ្វីដែលជាការពិត និងអ្វីដែលក្លែងក្លាយ។ ជាមួយគ្នានេះ ព័ត៌មានក្នុងទម្រង់ Information Disorder ក៏កំពុងមានការរីកសាយភាយយ៉ាងខ្លាំងនៅលើថ្នាលបណ្តាញសង្គម ដែលធ្វើឱ្យការកើនឡើងនេះ

បានក្លាយជាបញ្ហាប្រឈមសកលមួយ ដោយហេតុថាព័ត៌មានបែបនេះគ្របដណ្ដប់លើសពីផ្នែកនយោបាយ និងបានរាលដាលលើគ្រប់ទិដ្ឋភាពនៃព័ត៌មាន ដែលធ្វើឱ្យទំនុកចិត្តលើប្រព័ន្ធផ្សព្វផ្សាយបានជួបប្រទះនូវការប្រែប្រួល និងធ្វើឱ្យមានផលប៉ះពាល់ជាច្រើន ដូចជា៖



## ផលប៉ះពាល់កម្រិតបុគ្គល

ការរីកសាយភាយនៃព័ត៌មានក្នុងទម្រង់ Information Disorder អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើសមត្ថភាពនៃការគិតពិចារណា ដែលបង្កឱ្យកើតមានការបាត់បង់ម្ចាស់ការលើការសម្រេចចិត្ត (Cognitive Captivity)។ ការរស់នៅក្នុងសង្គមមួយដែលមានព័ត៌មានបែបនេះជារៀងរាល់ថ្ងៃ សាធារណជនងាយនឹងបាត់បង់សមត្ថភាពក្នុងការបែងចែកខុសត្រូវ ដែលនាំឱ្យការសម្រេចចិត្តសំខាន់ៗនៅក្នុងការរស់នៅប្រចាំថ្ងៃ ដូចជា ការបោះឆ្នោត ការវិនិយោគហិរញ្ញវត្ថុ ឬការថែទាំសុខភាព ត្រូវធ្វើឡើងដោយផ្អែកលើទិន្នន័យមិនពិតប្រាកដ។ ទន្ទឹមនេះ ព័ត៌មានបែបនេះក៏អាចបង្កជាបញ្ហាផ្លូវចិត្ត និងអសន្តិសុខផ្ទាល់ខ្លួនផងដែរ តាមរយៈទម្រង់នៃព័ត៌មាន Malinformation ដូចជា ការទម្លាយរូបភាពឯកជន ឬការផ្សព្វផ្សាយព័ត៌មានពិតក្នុងចេតនាបង្ខូចឈ្មោះ ដែលអាចបំផ្លាញអនាគត, ការងារ និងកិត្តិយសរបស់បុគ្គលម្នាក់ៗក្នុងរយៈពេលខ្លី រហូតអាចបង្កជាជំងឺបាក់ទឹកចិត្ត ឬការគំរាមកំហែងដល់អាយុជីវិតទៀតផង។



## ផលប៉ះពាល់កម្រិតសង្គម

ផលប៉ះពាល់កម្រិតសង្គមនៃវិបត្តិនេះ បានស្តែងចេញតាមរយៈការបាត់បង់នូវទំនុកចិត្តសង្គម (Erosion of Social Capital) និងការបែងចែកបក្សពួកនិយម (Hyper-Polarization)។ នៅក្នុងបរិបទនាពេលបច្ចុប្បន្ន បញ្ហាប្រឈមធំបំផុតមិនមែនត្រឹមតែជាការដាក់សម្ពាធផ្នែកគតិយុត្តលើស្ថាប័នព័ត៌មាននោះទេ ប៉ុន្តែជាការបាត់បង់ទំនុកចិត្តរបស់សាធារណជនមកលើប្រភពព័ត៌មានទាំងអស់រាប់ទាំងសារព័ត៌មានវិជ្ជាជីវៈផងដែរ។ របត់នេះធ្វើឱ្យសាធារណជនងាកទៅជឿជាក់លើព័ត៌មានណាដែលស្របនឹងចំណង់ចំណូលចិត្ត ឬត្រូវបានរុញច្រានដោយប្រព័ន្ធ Algorithms នៃបណ្តាញសង្គមផ្ទាល់ខ្លួន ដោយលែងសូវខ្វល់ខ្វាយពីការពិត ដែលនាំឱ្យសង្គមលែងមាន "ការពិតរួម (Shared Truth)" ទាំងក្នុងរង្វង់ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ព្រមទាំងរវាងប្រជាពលរដ្ឋ និងស្ថាប័ននានា។



## ផលប៉ះពាល់កម្រិតនយោបាយ

ផលប៉ះពាល់កម្រិតនយោបាយនេះ កំពុងបង្កើតជាក្ដីបារម្ភយ៉ាងខ្លាំង ជាពិសេសចំពោះដំណើរការបោះឆ្នោត ព្រមទាំងតម្លៃនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ គោលបំណងពិតប្រាកដនៃយុទ្ធនាការព័ត៌មានក្នុងទម្រង់បែបនេះ មិនមែនបង្កើតឡើងដើម្បីបញ្ចុះបញ្ចូលឱ្យសាធារណជនជឿជាក់លើខ្លឹមសារទាំងនោះថាជាការពិតឡើយ ប៉ុន្តែគឺដើម្បីជះឥទ្ធិពលលើការកំណត់របៀបវារៈ (Agenda-setting) ពោលគឺការបង្វែរទិសដៅនៃការគិតរបស់ពលរដ្ឋចំពោះបញ្ហាសំខាន់ៗ និងការបង្កើតភាពល្អក់កករនៅក្នុងប្រព័ន្ធព័ត៌មាន សំដៅធ្វើឱ្យចុះខ្សោយនូវការត្រិះរិះពិចារណា និងការសម្រេចចិត្តដ៏ត្រឹមត្រូវក្នុងការបោះឆ្នោត។ ទន្ទឹមនេះ ក្រុមជនខិលខូចក៏អាចអាស្រ័យផលពីភាពស្រពេចស្រពិលនៃព័ត៌មានដើម្បីប្រឌិតរឿងរ៉ាវ ដូចជា បញ្ហាព្រំដែន សាសនា ឬសេដ្ឋកិច្ច សំដៅញុះញង់ឱ្យមានបាតុកម្ម បង្កភាពចលាចល និងគំរាមកំហែងដល់ស្ថិរភាពសន្តិសុខជាតិផងដែរ។



## ផលប៉ះពាល់កម្រិតសេដ្ឋកិច្ច

ការកើនឡើងនៃព័ត៌មានក្នុងទម្រង់ Information Disorder មិនត្រឹមតែផ្តល់ផលប៉ះពាល់ដល់បុគ្គល, សង្គម និងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏បានជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចផងដែរ។ ជាក់ស្តែង ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីអស្ថិរភាព ឬការដួលរលំនៃគ្រឹះស្ថានធនាគារណាមួយ ព្រមទាំងការប្រឌិតព័ត៌មានដើម្បីបំភ្លែតតម្លៃភាគហ៊ុន (Stock Manipulation) គឺអាចធ្វើឱ្យសាធារណជនមានការភ័យស្លន់ស្លោ រហូតសម្រុកទៅដកប្រាក់ពីធនាគារក្នុងពេលតែមួយ (Bank Run) ដែលសកម្មភាពនេះអាចរុញច្រានឱ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ ដែលអាចនាំឱ្យសេដ្ឋកិច្ចជាតិទាំងមូលធ្លាក់ចូលក្នុងស្ថានភាពជាប់គាំង។



## III. វិធីសាស្ត្រផ្ទៀងផ្ទាត់ Information Disorders

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា បាននាំមកនូវលំហូរនៃ «Disinformation», «Misinformation» និង «Malinformation» ដែលអាចបង្កើតជាភាពវឹកវរ, ការយល់ច្រឡំ និងការបាត់បង់ទំនុកចិត្តក្នុងសង្គម។ ការទប់ស្កាត់ការឆ្លងរាលដាលនៃព័ត៌មានទាំងនេះ មិនមែនជាកាតព្វកិច្ចរបស់ស្ថាប័នណាមួយតែម្នាក់ឯងនោះទេ ប៉ុន្តែទាមទារនូវការចូលរួមពីប្រជាជនទាំងអស់គ្នា ក្នុងនាមជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយការទទួលខុសត្រូវ។ ដើម្បីការពារ និងប្រយុទ្ធប្រឆាំងនឹង Information Disorder យើងគួរស្វែងយល់ និងអនុវត្តនូវវិធានការគន្លឹះសំខាន់ៗមួយចំនួន ដូចជា៖

- **បង្កើតទម្លាប់ទទួលព័ត៌មានពីប្រភពចម្រុះ៖** ការតាមដានព័ត៌មានពីប្រភព និងស្ថាប័នសារព័ត៌មានផ្សេងៗគ្នា ជួយឱ្យអ្នកទទួលបានព័ត៌មានជុំវិញខ្លួនបានទូលំទូលាយ។ ប្រសិនបើព្រឹត្តិការណ៍ណាមួយត្រូវបានចុះផ្សាយ និងផ្ទៀងផ្ទាត់ដូចៗគ្នាដោយព័ត៌មានល្បីៗជាច្រើន នោះភាគរយដែលជាព័ត៌មានពិតគឺមានកម្រិតខ្ពស់។ ការស្វែងរករហ័សនៅលើ Google អាចជួយអ្នកផ្ទៀងផ្ទាត់មើលថា តើមានប្រភពគួរឱ្យទុកចិត្តផ្សេងទៀតកំពុងជជែកដេញដោលពីប្រធានបទនោះដែរឬទេ។ ប្រសិនបើគ្មានស្ថាប័នណាមួយចុះផ្សាយ នោះលទ្ធភាពដែលជាព័ត៌មានក្លែងក្លាយ គឺមានខ្ពស់ណាស់។

- **វាយតម្លៃពីភាពគួរឱ្យទុកចិត្តនៃប្រភពដោយការពិចារណា៖** ពេលមានមន្ទិលសង្ស័យលើព័ត៌មានណាមួយ ចាំបាច់ត្រូវស្រាវជ្រាវបន្ថែម ឬដាក់ជាសំណួរដេញដោល។ ចំពោះព័ត៌មានដែលឃើញនៅលើបណ្តាញសង្គម វិធីសាស្ត្រដ៏ល្អបំផុតដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត គឺការស្រាវជ្រាវស្វែងរកប្រភពដើម។ ប្រសិនបើព័ត៌មាននោះបានមកពីប្រភពដែលមិនសូវមានឈ្មោះបោះសំឡេង ឬផ្ទុយស្រឡះពីដំបូន្មានរបស់អ្នកជំនាញ ចូលបង្កើនការប្រុងប្រយ័ត្ន ហើយកត់ចំណាំទុកថាគណនី ឬទំព័របណ្តាញសង្គមនោះមិនមែនជាប្រភពល្អសម្រាប់តាមដានបន្តទៀតឡើយ។

- **ពិនិត្យស្រាវជ្រាវលើរូបភាព ឬវីដេអូ៖** ការបំភ័ន្តព័ត៌មានក៏អាចធ្វើឡើង តាមរយៈមាតិកា Multimedia ដែលមិនមែនជាអត្ថបទអក្សរផងដែរ។ ដូច្នេះ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅពេលឃើញមាតិកាបែបទស្សនីយភាព (រូបភាព ឬវីដេអូ) ដែលភ្ជាប់មកជាមួយអត្ថបទព័ត៌មាន ព្រោះថារូបភាព និងវីដេអូកាត់តគឺជាល្បិចកលទូទៅនៅក្នុងយុទ្ធនាការបំភ័ន្តព័ត៌មាន។ ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវច្បាស់លាស់ និងបរិបទពិតប្រាកដនៃព័ត៌មានទាំងនោះ។ អត្ថបទព័ត៌មានមិនពិតជាច្រើន តែងតែប្រើប្រាស់រូបភាពដែលត្រូវបានកាត់ត (Photoshop) ឬយកចេញពីគេហទំព័រផ្សេងទៀតដែលមិនពាក់ព័ន្ធគ្នា។ ជួនកាលប្រសិនបើអ្នកគ្រាន់តែសង្កេតមើលរូបភាពនោះឱ្យបានហ្មត់ចត់ អ្នកអាចមើលដឹងថាត្រូវបានកែប្រែឬក៏អត់។ វិធីម្យ៉ាងទៀត គឺការប្រើប្រាស់ឧបករណ៍ស្វែងរកប្រភពរូបភាពចាស់ ដូចជា Google Reverse Image Search ជាដើម។ វិធីនេះ ជួយបង្ហាញអ្នកថាតើរូបភាពដដែលនោះ ធ្លាប់ត្រូវបានគេយកទៅប្រើប្រាស់ក្នុងបរិបទផ្សេងទៀតដែរឬទេ។

- **ស្វែងរកភស្តុតាង៖** អ្នកដែលកែច្នៃបន្លំព័ត៌មាន តែងតែប្រើល្បិច «រើសយកតែការពិតមួយផ្នែក» (Cherry-pick) ដែលចំណេញដល់ពួកគេ ឬយកការពិតមកទ្បុកឡំជាមួយការកុហក ដើម្បីបង្វែរដាន និងធ្វើឱ្យគេភាន់ច្រឡំ។ ការអះអាងណាដែលមើលទៅហាក់ដូចជាខុសពីធម្មតា ឬអស្ចារ្យហួសហេតុ គឺទាមទារឱ្យមានភស្តុតាងជាក់លាក់មកបញ្ជាក់។ ដូច្នេះ ត្រូវផ្ទៀងផ្ទាត់ការអះអាងទាំងនោះជាមួយប្រភពផ្លូវការ ដែលអាចទុកចិត្តបានជានិច្ច។

- **គាំទ្រ និងចែករំលែកសំឡេងរបស់អ្នកជំនាញ៖** ចូលរួមគាំទ្រអ្នកជំនាញពិតប្រាកដដែលមានស្នាដៃ និងការទទួលស្គាល់ច្បាស់លាស់ក្នុងជំនាញរបស់ពួកគេ។ រាល់ពេលទទួលបានខ្លឹមសារអ្វីមួយហើយស្គាល់ប្រភពហើយនោះ អ្វីដែលសំខាន់បន្ទាប់គឺត្រូវស្វែងយល់ពីប្រវត្តិ និងកម្រិតវប្បធម៌របស់អ្នកនិពន្ធ។ តើអ្នកជំនាញរូបនោះមានសញ្ញាបត្រជាន់ខ្ពស់ពាក់ព័ន្ធនឹងប្រធានបទនេះដែរឬទេ? តើពួកគាត់មានបទពិសោធការងារប៉ុន្មានឆ្នាំក្នុងវិស័យនេះ? ហើយតើជាព័ត៌មានដែលបានឆ្លងកាត់ការត្រួតពិនិត្យតាមស្តង់ដា (Peer-reviewed) ពីស្ថាប័នដែលគួរឱ្យទុកចិត្តដែរឬទេ?

- **វាយបកពាក្យចចាមអារ៉ាម និងពន្យល់ពីចំណុចខុសឆ្គង៖** នៅពេលអ្នកមានហេតុផល និងភស្តុតាងពិតប្រាកដហើយ ត្រូវពន្យល់បកស្រាយត្រង់ៗ ដើម្បីចៀសវាងការរំលេច ឬនិយាយដដែលៗពីព័ត៌មានមិនពិតទាំងនោះ។ ការពន្យល់យ៉ាងលម្អិតពីមូលហេតុដែលធ្វើឱ្យព័ត៌មាននោះខុស គឺមានប្រសិទ្ធភាពជាងការគ្រាន់តែប្រាប់គេថាជា "ព័ត៌មានក្លែងក្លាយ" តែម្យ៉ាង។ ត្រូវចូលរួមរាយការណ៍យ៉ាងសកម្មរាល់ករណីបំភ័ន្តព័ត៌មាន និងការនិយាយស្តីបែបស្អប់ខ្ពើម (Hate Speech) ទៅកាន់អាជ្ញាធរពាក់ព័ន្ធ ឬទៅកាន់ក្រុមហ៊ុនគ្រប់គ្រងបណ្តាញផ្សព្វផ្សាយទាំងនោះ។

- **លើកកម្ពស់ការគិតដោយពិចារណា៖** ត្រូវរួមគ្នាបណ្តុះវប្បធម៌នៃការគិតដោយពិចារណា និងការយល់ដឹងពីប្រព័ន្ធផ្សព្វផ្សាយ (Media Literacy) នៅក្នុងសហគមន៍ ដើម្បីបង្កើតភាពស៊ាំប្រឆាំងនឹងការបំភ័ន្តព័ត៌មាន ក៏ដូចជាត្រូវចេះដាក់ការសង្ស័យ និងចេះផ្ទៀងផ្ទាត់ព័ត៌មានដោយឯករាជ្យ ដើម្បីកាត់បន្ថយឥទ្ធិពលនៃសាច់រឿងដែលគេប្រឌិតឡើងក្នុងន័យបោកប្រាស់។

## IV. សារៈសំខាន់នៃការយល់ដឹងអំពី Information Disorder

នៅក្នុងសម័យកាលមួយ ដែលមានលំហូរព័ត៌មានដ៏លើសលប់ ការយល់ដឹងអំពី Information Disorder គឺជាគន្លឹះយុទ្ធសាស្ត្រក្នុងការការពារបុគ្គល គ្រួសារ និងសង្គមជាតិ តាមរយៈទិដ្ឋភាពសំខាន់ៗចំនួន ៣ ៖

- **ទី១. ការពារការសម្រេចចិត្តខុសឆ្គងលើសន្តិសុខ និងសុខភាពផ្ទាល់ខ្លួន៖** នៅគ្រប់កម្រិតទាំងអស់ ចាប់តាំងពីកម្រិតរដ្ឋាភិបាលរហូតដល់បុគ្គលម្នាក់ៗ រាល់ការសម្រេចចិត្តត្រូវតែផ្អែកលើការពិត និងវិទ្យាសាស្ត្រជាមូលដ្ឋាន ព្រោះការសម្រេចចិត្តខុសឆ្គងណាមួយ សុទ្ធតែអាចរុញច្រានឱ្យទៅប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត។ ជាក់ស្តែង ក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ អង្គការសុខភាពពិភពលោក (WHO) បានប្រើប្រាស់ពាក្យ "Infodemic" ដើម្បីសម្គាល់ព័ត៌មានខុសឆ្គង ជុំវិញវិធីសាស្ត្រព្យាបាលបែបប្រថុយប្រថាន ដែលបានបង្កឱ្យមនុស្សជាច្រើនត្រូវរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ។
- **ទី២. ការរក្សាស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម៖** ការយល់ដឹងពី Information Disorder ជួយកាត់បន្ថយការរីករាលដាលនៃទស្សនៈជ្រុលនិយម និងការរើសអើងនានា ដូចជា ពូជសាសន៍, សាសនា, យេនឌ័រ, និន្នាការផ្លូវភេទ, សញ្ជាតិ, ឋានៈសង្គម-សេដ្ឋកិច្ច ឬស្ថានភាពអន្តោប្រវេសន៍ ដែលជាឫសគល់នៃអំពើអសីលធម៌ និងការបែកបាក់ក្នុងសង្គម។
- **ទី៣. ការការពារលទ្ធិប្រជាធិបតេយ្យ៖** ចំណេះដឹងលើបញ្ហានេះ ជួយពង្រឹងសមត្ថភាពរិះគន់ និងការគិតបែបស៊ីជម្រៅ (Critical Thinking) របស់ពលរដ្ឋ ចៀសវាងការធ្លាក់ក្នុងអន្ទាក់នៃការញុះញង់ ឬការជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោត។

គួរបញ្ជាក់ផងដែរថា ក្នុងស្ថានភាពអាសន្ន វិបត្តិនៃលំហូរព័ត៌មានបែប Information Disorder មិនត្រឹមតែធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនសម្ពាធផ្លូវចិត្តយ៉ាងខ្លាំងដល់សាធារណជន។ ការដោះស្រាយបញ្ហានេះ ទាមទារឱ្យមានការកែប្រែឥរិយាបថ ជំនឿ និងបទដ្ឋានសង្គម (Social Norms) ជុំវិញវប្បធម៌នៃការទទួល និងការចែកចាយព័ត៌មាន។ ផ្អែកលើការសាកល្បង និងអនុវត្តកន្លងមក ស្ថាប័នសារព័ត៌មាន ក្រុមស្រាវជ្រាវ សង្គមស៊ីវិល និងក្រុមហ៊ុនបច្ចេកវិទ្យាជុំវិញពិភពលោក បានរួមគ្នាប្រើប្រាស់វិធានការឆ្លើយតប ដើម្បីទប់ស្កាត់ និងកែតម្រូវព័ត៌មានប្រភេទនេះ ដូចជា៖

- **ការគ្រប់គ្រង និងត្រួតពិនិត្យខ្លឹមសារលើបណ្តាញសង្គម៖** បណ្តាញសង្គមនានាបានដាក់ចេញនូវយន្តការរាយការណ៍ផ្ទៃក្នុង, ការដាក់ស្លាកសញ្ញាព្រមាន និងការកាត់បន្ថយអាទិភាពនៃការបង្ហាញ (Downranking) ដើម្បីសម្គាល់ ឬលុបចោលនូវរាល់ខ្លឹមសារដែលបង្កហានិភ័យ និងគ្រោះថ្នាក់។ ជាទូទៅ រាល់ការបង្ហោះ (Posts) ណាដែលល្មើសនឹងគោលការណ៍ នឹងត្រូវកាត់បន្ថយលទ្ធភាពនៃការមើលឃើញជាសាធារណៈ ហើយក្នុងករណីដែលមានកម្រិតល្មើសធ្ងន់ធ្ងរ ខ្លឹមសារទាំងនោះនឹងត្រូវលុបចេញពីប្រព័ន្ធភ្លាមៗ។ បន្ថែមលើនេះ ចំពោះគណនីណាដែលប្រព្រឹត្តខុសឆ្គងដដែលៗ នឹងត្រូវប្រឈមមុខនឹងការផ្អាកដំណើរការជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។

- **ការបង្កើនអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ៖** ដំណោះស្រាយបង្ការដ៏សំខាន់បំផុត គឺការបង្កើនអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយតាមរយៈការរួមបញ្ចូលកម្មវិធីសិក្សានៅតាមសាលារៀន និងសហគមន៍មូលដ្ឋាន។ គោលដៅចម្បង គឺការបណ្ដុះបណ្ដាលសាធារណជនឱ្យមានសមត្ថភាពក្នុងការសម្គាល់រាល់ការបំភ័ន្តក៏ដូចជាភាពលម្អៀងនៅក្នុងខ្លឹមសារព័ត៌មាន ដើម្បីការពារកុំឱ្យការយល់ឃើញ និងការវាយតម្លៃរបស់ពួកគេ ត្រូវរងឥទ្ធិពលអវិជ្ជមានពីព័ត៌មានមិនពិតដោយមិនដឹងខ្លួន។

- **ការធ្វើសមាហរណកម្មបច្ចេកវិទ្យា AI៖** បញ្ញាសិប្បនិម្មិត (AI) និងឧបករណ៍បច្ចេកទេសកម្រិតខ្ពស់ត្រូវបានយកមកប្រើប្រាស់ជាឧបករណ៍យុទ្ធសាស្ត្រក្នុងការតាមដាន, គូសផែនទីលំហូរព័ត៌មាន (Information Mapping) និងស្ទាក់ចាប់ព័ត៌មានមិនពិតនៅគ្រប់ប្រព័ន្ធផ្សព្វផ្សាយ មុនពេលរីកសាយភាយទៅដល់សាធារណជនទូទៅ។

- **Information Inoculation៖** ផ្អែកលើទ្រឹស្ដីចិត្តវិទ្យា វិធីសាស្ត្រនេះមានដំណើរការដូចគ្នានឹងវ៉ាក់សាំងការពារជំងឺ ដោយបានផ្ដល់នូវការបំពាក់បំប៉នចំណេះដឹងទុកជាមុន សំដៅបង្ហាត់បង្រៀនផ្នត់គំនិតរបស់មនុស្សឱ្យចេះវិភាគ, ចោទសួរ និងបដិសេធព័ត៌មានមិនពិត មុនពេលពួកគេជឿលើរឿងរ៉ាវអ្វីមួយ។ ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រនេះនឹងរឹតតែខ្ពស់ ប្រសិនបើប្រជាជនមានគ្រឹះអក្ខរកម្មឌីជីថលរួចជាស្រេច។

- **ការលើកកម្ពស់ការផ្សព្វផ្សាយដើម្បីប្រយោជន៍សាធារណៈ៖** ការផលិតមាតិកាដែលបម្រើដល់ប្រយោជន៍សាធារណៈ ប្រកបដោយភាពទាក់ទាញ និងគួរឱ្យទុកចិត្ត គឺជាយន្តការទប់ទល់ដ៏មានឥទ្ធិពលមួយ។  ការសិក្សាស្រាវជ្រាវបានបង្ហាញថា វិធីសាស្ត្រនិទានរឿង ឬការសម្ដែងរឿង (Storytelling ឬ Drama) អាចជំរុញឱ្យមានការរៀនសូត្រតាមបែបសង្គម (Social Learning) យ៉ាងមានប្រសិទ្ធភាព។ តាមរយៈការសង្កេតមើលលទ្ធផលនៃការសម្រេចចិត្តរបស់តួអង្គ ទស្សនិកជននឹងចាប់ផ្ដើមឆ្លុះបញ្ចាំងមកលើខ្លួនឯង រហូតឈានដល់ការកែប្រែឥរិយាបថ និងទម្លាប់រស់នៅតាមបែបវិជ្ជមាន។

## V. ករណីសិក្សា

### ប្រទេសកម្ពុជា

ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាបានរីកចម្រើនយ៉ាងខ្លាំងក្លា ជាពិសេសនៅក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ ជាមួយភាពចម្រុះទាំងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយបែបទំនើបដែលអាចផ្ដល់ព័ត៌មានទៅប្រជាពលរដ្ឋបានគ្រប់ច្រកល្ហក និងគ្រប់ពេលវេលាទាំងអស់។ ប៉ុន្តែ ការរីកចម្រើននេះក៏នាំមកនូវបញ្ហាថ្មីៗ ដូចជា ព័ត៌មានក្លែងក្លាយ, ការបំភ្លៃការពិត, ការប្រើប្រាស់ព័ត៌មានក្នុងគោលបំណងនយោបាយ និងការបង្កចលាចលនានា ដែលប៉ះពាល់សណ្ដាប់ធ្នាប់ក្នុងសង្គម។ បញ្ហាប្រឈមនៃការរីករាលដាលព័ត៌មានទាំងអស់នេះ បាននិងកំពុងរីករាលដាលឆ្លងដែនយ៉ាងរហ័សនៅក្នុងតំបន់ និងសកលលោក ដែលនេះជាវិបត្តិមួយសម្រាប់សកលលោក រួមទាំងកម្ពុជាផងដែរ ដែលទាមទារឱ្យមានការដាក់ចេញនូវវិធានការឆ្លើយតប និងទប់ស្កាត់ជាបន្ទាន់ ព្រោះបានបង្កឱ្យ

សាធារណជនមានការភាន់ច្រឡំ, កាត់បន្ថយទំនុកចិត្តលើស្ថាប័នរដ្ឋនិងឯកជន, បំផ្លាញសុខដុមនីយកម្មសង្គម, ប៉ះពាល់ដល់សន្តិសុខជាតិ ព្រមទាំងអាចធ្វើឱ្យរង្គោះរង្គើដល់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសជាដៃគូទៀតផង។

នាពេលបច្ចុប្បន្ន ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គមនៅកម្ពុជាមានការកើនឡើងគួរកត់សម្គាល់ ដែលគិតត្រឹមឆ្នាំ២០២៥ មានអ្នកប្រើប្រាស់បណ្តាញសង្គមជាង **១៤លានគណនី** ដោយក្នុងនោះ បណ្តាញសង្គម ដែលពេញនិយម រួមមាន Facebook, TikTok, Messenger និង Instagram។ បណ្តាញសង្គមទាំងនេះ សុទ្ធសឹងតែកំពុងមានសក្តានុពល និងមានតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកព័ត៌មាន ទាំងព័ត៌មានវិជ្ជមាន និងព័ត៌មានអវិជ្ជមាន, ទាំងព័ត៌មានពិត និងព័ត៌មានក្លែងក្លាយ។ ជាក់ស្តែង ក្នុងឆ្នាំ២០២៥ ក្រសួងព័ត៌មាន បានរកឃើញព័ត៌មានក្លែងក្លាយជិត ៤០០០ករណី ភាគច្រើនពាក់ព័ន្ធនឹងជម្លោះព្រំដែនកម្ពុជា-ថៃ។ ការចេញផ្សាយព័ត៌មានក្នុងទម្រង់បែបនេះ មិនមែនជាសេរីភាពសារព័ត៌មាន និងសេរីភាពការបោះពុម្ពផ្សាយនោះទេ ប៉ុន្តែគឺជាការរំលោភបំពានលើច្បាប់។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ បាននិងកំពុងធ្វើការយ៉ាងជាប់លាប់ក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្នុងទម្រង់ Information Disorder នេះ ដោយសកម្មភាពនេះមិនមែនជាការគាបសង្កត់លើសិទ្ធិសេរីភាពនៃការបោះពុម្ពផ្សាយ និងសេរីភាពនៃការបញ្ចេញមតិ ឬសេរីភាពសារព័ត៌មាននោះទេ ប៉ុន្តែជាការផ្តល់នូវសុវត្ថិភាព និងជាការការពារនូវសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលត្រូវទទួលបាននូវព័ត៌មានពិត និងព័ត៌មានដែលមានសុវត្ថិភាព សម្រាប់ប្រជាជនរាប់លាននាក់នៅកម្ពុជា។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងទាំងនោះ រួមមាន៖

## ◉ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយ នៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏មានមាត្រា ដែលបានចែងពីវិធានសម្រាប់គ្រប់គ្រងរាល់សកម្មភាពនានាពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មាន។ ជាក់ស្តែង មាត្រា ៤១ បានចែងថា **«ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន, សេរីភាពខាងសារព័ត៌មាន, សេរីភាពខាងបោះពុម្ពផ្សាយ, សេរីភាពខាងប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់»**។

## ◉ ច្បាប់ស្តីពីរបបសារព័ត៌មាន

ច្បាប់ស្តីពីរបបសារព័ត៌មាន ត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥

មាន ២១មាត្រា ដែលច្បាប់នេះកំណត់ពីរបបសារព័ត៌មាន និងធានារ៉ាប់រងសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយ។ ប៉ុន្តែច្បាប់នេះផ្តោតសំខាន់ទៅលើការបោះពុម្ព ឬផ្សាយបន្តបែបបុរាណ ដោយពុំទាន់បញ្ចូលនូវកថាខណ្ឌពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល ឱ្យបានទូលំទូលាយនៅឡើយទេ។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃសង្គម បច្ចេកវិទ្យា និងចូលរួមលុបបំបាត់ព័ត៌មានក្លែងក្លាយ ក្រសួងព័ត៌មាន បាននិងកំពុងពិភាក្សា ដើម្បីរៀបចំច្បាប់នេះឡើងវិញ សំដៅធានាដល់ការអនុវត្តវិជ្ជាជីវៈសារព័ត៌មានប្រកបដោយក្រមសីលធម៌ និងធានាបាននូវបរិយាកាសប្រព័ន្ធផ្សព្វផ្សាយកាន់តែមានតម្លាភាព និងគុណភាពទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។

### គណៈកម្មការតាមដាន «ព័ត៌មានក្លែងក្លាយ»

ក្រសួងព័ត៌មាន បានសម្រេចបង្កើតគណៈកម្មការមួយ ដើម្បីតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។ គណៈកម្មការនេះមានភារកិច្ចតាមដានការផ្សាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយនានា និងដំណឹងមិនពិតនៅតាមបណ្តាញសង្គម ក៏ដូចជាធ្វើការឆ្លើយតបជូនសាធារណជនឱ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយដែលមានស្រាប់រាល់ពេលមានដំណឹង ឬព័ត៌មានក្លែងក្លាយ និងសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីរាំងខ្ទប់គេហទំព័រ និងគណនីទាំងឡាយណា ដែលផ្សាយព័ត៌មានមិនពិត និងចាត់វិធានការតាមច្បាប់។

### ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន

ក្រសួងព័ត៌មាន កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ បានប្រកាសឱ្យប្រើប្រាស់ និងផ្សព្វផ្សាយពី **ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន** ដើម្បីពង្រឹងក្រមសីលធម៌ក្នុងវិស័យសារព័ត៌មាន និងជាមូលដ្ឋានគ្រឹះដល់អ្នកសារព័ត៌មាន រួមទាំងអ្នកផលិតមាតិកា ដើម្បីស្វែងយល់។ ធម្មនុញ្ញនេះមានគោលបំណងបន្តធានាបរិយាកាសល្អប្រសើរសម្រាប់ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន ប្រកបដោយទំនុកចិត្ត, ប្រសិទ្ធភាព, គុណភាព និងការទទួលខុសត្រូវវិជ្ជាជីវៈ ជាផ្នែកសម្រាប់ការលើកកម្ពស់សេរីភាពខាងសារព័ត៌មាន និងការពារសុវត្ថិភាពអ្នកសារព័ត៌មាន។ ធម្មនុញ្ញនេះ កំណត់ទិដ្ឋភាពសំខាន់ៗដូចជា៖ ទី១. កំណត់និយាមអប្បបរមាសម្រាប់សកម្មភាពផ្សព្វផ្សាយព័ត៌មានគ្រប់ទម្រង់ និងតាមគ្រប់មធ្យោបាយ, ទី២. បណ្តុះ និងបញ្ជ្រាបផ្នត់គំនិតនៃការផ្សារភ្ជាប់សេរីភាពខាងសារព័ត៌មាន ជាមួយកាតព្វកិច្ច និងទំនួលខុសត្រូវក្នុងក្របខ័ណ្ឌច្បាប់, ទី៣. តម្រង់ទិសលើការប្រតិបត្តិក្រមសីលធម៌ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ និងទី៤. លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានពិត, ត្រឹមត្រូវ, គ្រប់ជ្រុងជ្រោយ ប្រកបដោយតុល្យភាព និងមានប្រភពច្បាស់លាស់ ព្រមទាំងចូលរួមបង្ការ, ទប់ស្កាត់ និងប្រឆាំងដំណឹងក្លែងក្លាយ, ព័ត៌មានក្លែងបន្លំ, ព័ត៌មានបំភ្លៃ និងព័ត៌មានភាន់ច្រលំ និងព័ត៌មានដែលមានលក្ខណៈខុសពីការពិត។

### ផែនការសកម្មភាពស្តីពីការកសាងនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ឆ្នាំ២០២៥-២០២៨

ក្រសួងព័ត៌មាន បានរៀបចំ **«ផែនការសកម្មភាពស្តីពីការកសាងនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ឆ្នាំ២០២៥-២០២៨»** ដែលមានវិសាលភាពសម្រាប់អនុវត្តចំពោះមន្ត្រីរាជការក្រសួងព័ត៌មាន និងអ្នកដែលធ្វើសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីកសាង និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ កម្រិតសញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់, បណ្ដុះបណ្ដាលជំនាញបច្ចេកទេសវិជ្ជាជីវៈ និងការគ្រប់គ្រងឱ្យស្របនឹងការវិវត្តផ្នែកបច្ចេកវិទ្យា និងតម្រូវការក្នុងសង្គម បង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព និងលើកកម្ពស់សមត្ថភាពការងារទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពីបណ្ដាប្រទេសក្នុងតំបន់ និងលើសកលលោក។

### ◉ វេទិកាពិភាក្សាមហាអនុតំបន់មេគង្គ សម្រាប់យុទ្ធនាការលុបបំបាត់ព័ត៌មានក្លែងក្លាយ

ក្រសួងព័ត៌មាន បានរៀបចំ **វេទិកាថ្នាក់តំបន់ ស្ដីពី យុទ្ធនាការប្រឆាំងព័ត៌មានក្លែងក្លាយ៖ ពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងព័ត៌មានបំភ្លៃ** បន្ទាប់ពីការអនុវត្តគម្រោងប្រឆាំងព័ត៌មានក្លែងក្លាយសម្រាប់អ្នកសារព័ត៌មាន (ដំណាក់កាលទី២) ក្រោមប្រធានបទ «ការកសាងទំនុកចិត្តក្នុងតំបន់, ភាពធន់នឹងប្រព័ន្ធឌីជីថល និងការចែករំលែកព័ត៌មានប្រកបដោយការទទួលខុសត្រូវ»។ វេទិកានេះដើរតួនាទីយ៉ាងសំខាន់សម្រាប់ការសន្ទនា, ការផ្លាស់ប្ដូរបទពិសោធគ្នាទៅវិញទៅមក និងការពិភាក្សាស្ដីពីកិច្ចសហប្រតិបត្តិការជាក់ស្ដែង ដើម្បីទប់ស្កាត់ព័ត៌មានក្លែងក្លាយ, ព័ត៌មានភាន់ច្រឡំ, ព័ត៌មានក្លែងបន្លំ, ពាក្យចចាមអារ៉ាម, មាតិកាបំភ្លៃ, និងព័ត៌មានអនឡាញដែលបង្កគ្រោះថ្នាក់។ កិច្ចសហប្រតិបត្តិការនេះក៏បានរួមចំណែកក្នុងការពង្រឹងការយោគយល់គ្នាទៅវិញទៅមក, ទំនុកចិត្តសាធារណៈ, ភាពធន់នឹងប្រព័ន្ធឌីជីថល និងការចែករំលែកព័ត៌មានប្រកបដោយការទទួលខុសត្រូវ ក្នុងបណ្ដាប្រទេសជាសមាជិកមហាអនុតំបន់មេគង្គ។

### ◉ យុទ្ធនាការ «និយាយថាទេ ចំពោះព័ត៌មានក្លែងក្លាយ!»

ក្រសួងព័ត៌មាន កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥ បានបើក **យុទ្ធនាការ «និយាយថាទេ ចំពោះព័ត៌មានក្លែងក្លាយ!»** រយៈពេល ១២ខែ ក្នុងបំណងផ្លាស់ប្ដូរឥរិយាបថរបស់ប្រជាជន ពិសេសលើបណ្ដាញសង្គម ដើម្បីរួមគ្នាទប់ស្កាត់ការរីករាលដាលព័ត៌មានក្លែងក្លាយ។ យុទ្ធនាការនេះបានបញ្ចប់ទៅដោយជោគជ័យ ដោយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៦ ក្រសួងព័ត៌មានក៏បានប្រកាសបើក **យុទ្ធនាការ «និយាយថាទេ ចំពោះព័ត៌មានក្លែងក្លាយ!»** ជំហានទី២ ក្រោមប្រធានបទ «ពង្រឹងអក្ខរកម្មព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីសុវត្ថិភាពព័ត៌មាន» ដោយចាប់ផ្ដើមចេញពីរាជធានីភ្នំពេញ នៅទីតាំងវិទ្យាល័យហ៊ុន សែន ប៊ុនរ៉ានី វត្តភ្នំ។ យុទ្ធនាការនេះ នឹងបញ្ជ្រាបចំណេះដឹងផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ និងផលប៉ះពាល់នៃព័ត៌មានក្លែងក្លាយដល់យុវវ័យ សំដៅពង្រឹងភាពធន់របស់ពួកគេក្នុងការចូលរួមបង្ការ, ទប់ស្កាត់ និងលុបបំបាត់ព័ត៌មានក្លែងក្លាយ ព្រោះយុវវ័យក្នុងសម័យឌីជីថលមានការប្រឈមខ្លាំងជាមួយការប្រើប្រាស់បច្ចេកវិទ្យា ដែលមិនបម្រើឱ្យផលប្រយោជន៍វិជ្ជមាន ប្រសិនបើមិនមានការអប់រំណែនាំ និងពង្រឹងផ្នែកអក្ខរកម្មឌីជីថល, អក្ខរកម្មព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយទេនោះ។

### អន្តរកម្មឌីជីថល និងអន្តរកម្មព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ

ការបណ្តុះបណ្តាលនេះ ពិតជាមានភាពចាំបាច់ ដើម្បីបង្កើតភាពធន់ក្នុងចំណោមអ្នកសារព័ត៌មាន និងអ្នកធ្វើសកម្មភាពក្នុងវិស័យព័ត៌មាន ជាពិសេសសាធារណជនទូទៅ ដើម្បីផលិតមាតិកា ដោយការទទួលខុសត្រូវ និងមានក្រមសីលធម៌ ក៏ដូចជាចៀសវាងការធ្លាក់ចូលក្នុងអន្ទាក់នៃព័ត៌មានក្លែងក្លាយ។ ក្នុងន័យនេះ ភាគីពាក់ព័ន្ធនានា ដូចជា ក្រសួង-ស្ថាប័ន, សង្គមស៊ីវិល និងគ្រឹះស្ថានអប់រំ តែងតែរៀបចំជាវគ្គបណ្តុះបណ្តាលនានា ដើម្បីឱ្យសាធារណជន ក៏ដូចជាអ្នកដែលនៅក្នុងវិស័យព័ត៌មានផ្ទាល់ អាចមានសមត្ថភាពក្នុងការសម្គាល់ និងឆ្លើយតបនឹងព័ត៌មានដែលបង្កគ្រោះថ្នាក់ទាំងនោះ។

### សហរដ្ឋអាម៉េរិក៖ ផែនទីបង្ហាញផ្លូវប្រជាធិបតេយ្យ លើការស្តាបនាភាពធន់ក្នុងសង្គមស៊ីវិល ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមជាសកលនៃការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ពេលវេលា និងធនធានយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានចំណាយលើការត្រួតពិនិត្យ និងតាមដានព័ត៌មាននៅលើបណ្តាញសង្គម, កម្មវិធីផ្ញើសារដែលមានសុវត្ថិភាពខ្ពស់ (Encrypted Chat Apps) ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយឌីជីថលផ្សេងទៀត ដែលកំពុងត្រូវបានគេយកទៅប្រើប្រាស់ក្នុងផ្លូវមិនត្រឹមត្រូវ និងកេងប្រវ័ញ្ច ដើម្បីបង្កឱ្យមានភាពចលាចលក្នុងបណ្តាប្រទេសប្រជាធិបតេយ្យ។ នាពេលនេះ សហរដ្ឋអាម៉េរិកផ្តោតការយកចិត្តទុកដាក់លើការបង្កើតផែនការសកម្មភាពជាក់លាក់ ដើម្បីស្តាបនាភាពធន់ក្នុងសង្គមស៊ីវិល សំដៅប្រឆាំងនឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល ក៏ដូចជាពង្រឹងសុចរិតភាពនៃវិស័យព័ត៌មានឌីជីថលក្នុងការគាំទ្រដល់របបប្រជាធិបតេយ្យ។ កិច្ចការនេះត្រូវចាប់ផ្តើមចេញពីការបង្កើនការយល់ដឹងរួមគ្នាអំពីរបៀបដែលបណ្តាញព័ត៌មានឌីជីថលដំណើរការ, របៀបដែលក្បួនដោះស្រាយបញ្ហា (Algorithmic), កំណត់ទម្រង់បរិបទព័ត៌មានរបស់អ្នកប្រើប្រាស់ និងរបៀបរៀបចំខ្លួនដើម្បីត្រៀមលក្ខណៈទប់ទល់នឹងផលប៉ះពាល់ដែលអាចកើតមានពីមាតិកាដែលបង្កើតឡើងដោយបច្ចេកវិទ្យា AI។

សហរដ្ឋអាម៉េរិកក៏កំពុងជំរុញឱ្យមានការឆ្លើយតបជាសកលមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសុចរិតភាពព័ត៌មាន ស្របតាមតម្លៃប្រជាធិបតេយ្យ, សេរីភាពក្នុងការបញ្ចេញមតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ ការិយាល័យ Cyberspace និងគោលនយោបាយឌីជីថល (CDP) នៃក្រសួងការបរទេសសហរដ្ឋអាម៉េរិក បានបង្កើតផែនទីបង្ហាញផ្លូវប្រជាធិបតេយ្យមួយ សម្រាប់អ្នករៀបចំគោលនយោបាយសកល សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីពង្រឹងភាពធន់ក្នុងសង្គមស៊ីវិល ប្រឆាំងនឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល។ ផែនទីបង្ហាញផ្លូវនេះផ្តល់នូវជំហានជាក់លាក់ប្រកបដោយភាពវិជ្ជមាន ដែលមានដូចជា៖

### ជំហានទី១៖ លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃបញ្ហាប្រឈមនៃការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល ដែលជាការគំរាមកំហែងដល់ដំណើរការ និងភាពរស់រវើកនៃសង្គម

ជំហានដំបូងក្នុងការដោះស្រាយបញ្ហាប្រឈមនៃការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល គឺត្រូវ

សង្កត់ធ្ងន់ថា បញ្ហានេះកំពុងបង្កជាការគំរាមកំហែងដល់អនាគតនៃរបបប្រជាធិបតេយ្យសកល។ ការធ្លាក់ចុះនៃសុចរិតភាពក្នុងវិស័យព័ត៌មានឌីជីថលសកល បានរួមចំណែកបំផ្លាញនូវទំនុកចិត្តរបស់ប្រជាពលរដ្ឋលើតម្លៃប្រជាធិបតេយ្យ និងស្ថាប័ននៅជុំវិញពិភពលោក។ ការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថលក៏អាចធ្វើឱ្យប៉ះពាល់ដល់ការយល់ឃើញរួមចំពោះតថភាពជាក់ស្តែង ដែលធ្វើឱ្យការឆ្លើយតបនឹងការគំរាមកំហែងសកល ដូចជា ការប្រែប្រួលអាកាសធាតុ ឬជំងឺរាតត្បាត កាន់តែមានភាពស្មុគស្មាញ និងពិបាកដោះស្រាយ។ ក្រុមមនុស្សខិលខូច បានទាញយកផលប្រយោជន៍ពីប្រព័ន្ធឌីជីថល ដើម្បីបង្កើតជាកិច្ចសន្ទនាទាំងនៅក្នុងប្រទេស និងឆ្លងដែន ព្រមទាំងធ្វើឱ្យជម្លោះក្នុងសង្គមកាន់តែធ្ងន់ធ្ងរ និងបង្កើនការបែកបាក់គ្នាកាន់តែខ្លាំង ទាំងនៅក្នុង និងរវាងសង្គមប្រជាធិបតេយ្យនានា។ ការការពារសុចរិតភាពនៃព័ត៌មានឌីជីថល គឺជារឿងចាំបាច់មិនអាចខ្វះបាន ដើម្បីការពាររបបប្រជាធិបតេយ្យនៅទូទាំងសកលលោក។ ហេតុដូច្នេះ ការស្តាបនាភាពធន់ក្នុងសង្គមស៊ីវិលប្រឆាំងនឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល គឺជាកាតព្វកិច្ចសម្រាប់សន្តិសុខជាតិ និងគោលនយោបាយការបរទេស។

- ***ជំហានទី២៖ ទទួលស្គាល់ថា ការស្តាបនាសុចរិតភាពព័ត៌មាន អាចដើរទន្ទឹមគ្នាជាមួយនឹងសេរីភាពនៃមតិ និងការបញ្ចេញមតិ***

ការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល ត្រូវបានទទួលស្គាល់ថាជាការគំរាមកំហែងដល់ការអនុវត្តសេរីភាពនៃមតិ និងការបញ្ចេញមតិ ជាជាងការចាត់ទុកត្រឹមតែជាផលប៉ះពាល់អវិជ្ជមានអចេតនាមួយដែលកើតចេញពីការការពារសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិសេរីភាពខាងមតិយោបល់ និងការបញ្ចេញមតិ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។

- ***មាត្រា ១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)៖*** មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពនៃមតិ និងការបញ្ចេញមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិយោបល់ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក, ការទទួល និងការផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាទស្សនៈនានា តាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយ ដោយមិនគិតពីព្រំដែនកំណត់ឡើយ។
- ***មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)៖*** ១. មនុស្សគ្រប់រូបត្រូវមានសិទ្ធិប្រកាន់មតិយោបល់ដោយគ្មានការជ្រៀតជ្រែក, ២. មនុស្សគ្រប់រូបត្រូវមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការស្វែងរក, ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងទស្សនៈគ្រប់ប្រភេទ ដោយមិនគិតពីព្រំដែនកំណត់ឡើយ ទោះជាតាមរយៈពាក្យសម្តី, តាមអត្ថបទសរសេរ ឬការបោះពុម្ព, តាមទម្រង់សិល្បៈ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយណាមួយផ្សេងទៀតដែលខ្លួនជ្រើសរើស។

ការទទួលបានព័ត៌មានដែលផ្អែកលើការពិត ជាពិសេសនៅក្នុងពេលនៃការបោះឆ្នោត គឺជារឿងសំខាន់ខ្វះមិនបានសម្រាប់ប្រជាពលរដ្ឋក្នុងការបង្កើតមតិយោបល់ និងការអនុវត្តសិទ្ធិរបស់ពួកគេ

រួមទាំងសិទ្ធិបោះឆ្នោតផងដែរ។ យើងត្រូវតែយល់ដឹងឱ្យបានគ្រប់ជ្រុងជ្រោយអំពីសេរីភាពនៃមតិ និងការបញ្ចេញមតិ ពោលគឺមិនត្រឹមតែសេរីភាពក្នុងការផ្សព្វផ្សាយព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសេរីភាពក្នុងការស្វែងរក និងទទួលព័ត៌មាន ព្រមទាំងសេរីភាពក្នុងការប្រកាន់មតិយោបល់ផងដែរ ជាពិសេសនៅក្នុងបរិបទឌីជីថល។ ធាតុផ្សំទាំងអស់នេះ សុទ្ធសឹងតែជាគ្រឹះដ៏មានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ។

សេរីភាពក្នុងការបញ្ចេញមតិតែងតែរងផលប៉ះពាល់បន្ថែមទៀត នៅពេលដែលបច្ចេកវិទ្យាត្រូវបានគេយកទៅប្រើប្រាស់ក្នុងផ្លូវខុស ដើម្បីបង្កឱ្យមានអំពើហិង្សាផ្អែកលើយេនឌ័រ ក្នុងគោលបំណងរារាំងដល់ការចូលរួមយ៉ាងពេញលេញ និងសកម្មរបស់ស្ត្រី, កុមារី និងក្រុមបុគ្គល LGBTQI+ នៅក្នុងឆាកនយោបាយ និងសង្គមស៊ីវិលដទៃទៀត។ នៅពេលដែលប្រជាពលរដ្ឋច្រើនជាងពាក់កណ្តាលនៃសង្គមជាតិ ត្រូវបានបង្ខំឱ្យដកថយពីការចូលរួមក្នុងសកម្មភាពសង្គមតាមប្រព័ន្ធអ៊ីនធឺណិត នោះនឹងបំផ្លាញដល់ការចូលរួមយ៉ាងពេញលេញក្នុងដំណើរការ និងការដេញដោលតាមបែបប្រជាធិបតេយ្យ។

### ◉ ជំហានទី៣៖ ពង្រឹងសមត្ថភាពថ្នាលឌីជីថលរបស់វិស័យឯកជន ដើម្បីលើកកម្ពស់សុចរិតភាពព័ត៌មាន

កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្នុងការគោរពសេរីភាពនៃការបញ្ចេញមតិ គួរតែមានអត្ថន័យទូលំទូលាយជាងការផ្តោតតែមួយផ្នែកលើសមត្ថភាពរបស់ "អ្នកប្រើប្រាស់" ក្នុងការបញ្ចេញមតិ ឬការផ្សព្វផ្សាយព័ត៌មាន។ ក្នុងន័យនេះ វាជាការចាំបាច់ដែលត្រូវទទួលស្គាល់ថា គោលការណ៍ណែនាំសហគមន៍ (Community Guidelines) និងគោលនយោបាយផ្ទៃក្នុងផ្សេងៗទៀតរបស់ថ្នាលឌីជីថលទាំងនោះ សុទ្ធតែដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ទម្រង់ និងរក្សាគុណភាពនៃកិច្ចសន្ទនាបែបស៊ីវិលនៅក្នុងសង្គម។ ថ្នាលឌីជីថលនៃវិស័យឯកជន ក៏អាចរួមចំណែកក្នុងការកសាងភាពធន់ក្នុងសង្គមស៊ីវិលប្រឆាំងនឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថលផងដែរ។ ជំហានដំបូងដ៏សំខាន់បំផុត គឺការបង្កើនតម្លាភាពរបស់បណ្តាញទាំងនោះ។ ការខ្វះការយល់ដឹងអំពីរបៀបដែលទំព័រព័ត៌មានឌីជីថល (Digital Information Feed) ត្រូវបានកំណត់ទម្រង់ឡើង បានធ្វើឱ្យប្រជាពលរដ្ឋមានភាពធន់តិចតួចក្នុងការទប់ទល់នឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល។ ការកើនឡើងនៃមាតិកាដែលបង្កើតឡើងដោយបច្ចេកវិទ្យា AI រួមមាន វីដេអូ ឬរូបភាពក្លែងបន្លំកម្រិតខ្ពស់/កម្រិតទាប (Deep/cheap fakes), សំឡេងក្លែងបន្លំ និងមាតិកាដទៃទៀត បានធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើង។ ថ្នាលឌីជីថលនៃវិស័យឯកជន អាចបង្កើនតម្លាភាព និងការទំនាក់ទំនង ផ្អែកលើចំណុច ដូចជា៖

- ការជំរុញ ឬបន្ថយលទ្ធភាពនៃការមើលឃើញមាតិកាដោយក្បួនដោះស្រាយ (Algorithmic Promotion and Demotion)
- គោលនយោបាយឯកជនភាព
- ការប្រើប្រាស់ និងការចែករំលែកទិន្នន័យរបស់អ្នកប្រើប្រាស់
- ការដាក់ស្លាកសម្គាល់លើមាតិកាដែលបង្កើតឡើងដោយបច្ចេកវិទ្យា AI។

## ផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាបច្ចេកវិទ្យា AI ជាពិសេសនៅក្នុងបរិបទនៃការបោះឆ្នោតសកលឆ្នាំ២០២៤

ការបង្កើតមាតិកាដោយបច្ចេកវិទ្យា AI កំពុងតែទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់មនុស្សជុំវិញពិភពលោក។ ភាគីពាក់ព័ន្ធនៅក្នុងសង្គមប្រជាធិបតេយ្យ ចាំបាច់ត្រូវទាញយកផលប្រយោជន៍ពីសន្ទុះនៃការចាប់អារម្មណ៍នេះ ដើម្បីបង្កើនល្បឿនក្នុងការកសាងភាពធន់នៃសង្គមស៊ីវិល ប្រឆាំងនឹងការបំភាយព័ត៌មានមិនពិតនានា។ បច្ចុប្បន្ន ឧបករណ៍ដែលដំណើរការដោយ Generative AI ត្រូវបានដាក់ឱ្យសាធារណជនប្រើប្រាស់ និងចរាចរនៅលើទីផ្សារយ៉ាងទូលំទូលាយ ដោយមិនទាន់មានការវាយតម្លៃ ឬយល់ដឹងឱ្យបានគ្រប់ជ្រុងជ្រោយ អំពីផលប៉ះពាល់នៃការយកឧបករណ៍ទាំងនេះទៅប្រើប្រាស់ក្នុងផ្លូវខុសឡើយ ដែលកត្តានេះអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់គុណភាព និងសុចរិតភាពនៃប្រព័ន្ធព័ត៌មាន។ សមត្ថភាពថ្មីៗក្នុងការបង្កើតមាតិកាសំយោគ (Synthetic Content) ត្រូវបានបើកចំហសម្រាប់មនុស្សគ្រប់រូប ដែលអាចយកទៅប្រើប្រាស់ទាំងក្នុងគោលបំណងច្នៃប្រឌិត និងក្នុងចេតនាទុច្ចរិត។ បច្ចេកវិទ្យា GAI អាចជួយសម្រួលដល់ក្រុមជនខិលខូច ក្នុងការកំណត់មុខសញ្ញាឯកជន (Micro-targeting) កាន់តែចំគោលដៅ ព្រមទាំងអាចផលិតព័ត៌មានបំភ្លៃក្នុងទ្រង់ទ្រាយធំដោយស្វ័យប្រវត្តិ ក្នុងតម្លៃកាន់តែទាប និងល្បឿនលឿនជាងមុន។ ហេតុដូច្នេះ ប្រជាពលរដ្ឋចាំបាច់ត្រូវអភិវឌ្ឍន៍សមត្ថភាព និងជំនាញឌីជីថលថ្មីៗឱ្យបានឆាប់រហ័ស ដើម្បីសម្របខ្លួន និងទប់ទល់នឹងផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានឡើងពីបច្ចេកវិទ្យា GAI នេះ។

បរិបទនៃការបោះឆ្នោតជាសកលក្នុងទ្រង់ទ្រាយធំកាលពីឆ្នាំ២០២៤ បានជំរុញឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់បន្ថែមទៀត លើទំនួលខុសត្រូវក្នុងការកាត់បន្ថយហានិភ័យនានា ដែលបង្កឡើងដោយបច្ចេកវិទ្យា Generative AI (GAI) មកលើសេរីភាពនៃការបញ្ចេញមតិ និងសុចរិតភាពនៃការបោះឆ្នោត។ ជាក់ស្តែង មាតិកាក្លែងបន្លំដែលផលិតដោយបច្ចេកវិទ្យា GAI នេះ ត្រូវបានគេយកទៅប្រើប្រាស់រួចមកហើយនៅក្នុងការបោះឆ្នោតនៅប្រទេសស្លូវ៉ាគី, ប៉ាគីស្ថាន, ឥណ្ឌូនេស៊ី និងបង់ក្លាដែស។ ព័ត៌មានមិនពិតដែលបង្កើតឡើងដោយបច្ចេកវិទ្យា AI មានសក្តានុពលខ្ពស់ក្នុងការបំភ្លៃកិច្ចសន្ទនាបែបស៊ីវិល, បង្វែរមតិសាធារណៈ និងប៉ះពាល់ដល់និទានកថាជុំវិញសុចរិតភាពនៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ។ នេះជារឿងដែលអាចមើលឃើញយ៉ាងច្បាស់ថា វិស័យព័ត៌មានឌីជីថលសកលអាចនឹងត្រូវជន់ជោរដោយវីដេអូ ឬរូបភាព Deepfakes និងប្រព័ន្ធផ្សព្វផ្សាយសំយោគ (Synthetic Media) ដែលត្រូវបានរចនាឡើងក្នុងគោលបំណងបោកប្រាស់ប្រជាពលរដ្ឋដែលអាចជះឥទ្ធិពលដល់អត្រាអ្នកទៅបោះឆ្នោត តាមរយៈការចែកចាយព័ត៌មានបំភ័ន្តជុំវិញដំណើរការបោះឆ្នោត។ កត្តាទាំងនេះ នឹងកាន់តែជំរុញឱ្យមានការព្រួយបារម្ភជាសាធារណៈកាន់តែខ្លាំង អំពីការលួចបន្លំសន្លឹកឆ្នោត។

ក្នុងន័យនេះ ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងបច្ចេកវិទ្យា GAI គឺលើកទឹកចិត្តឱ្យមានការវិនិយោគពីវិស័យឯកជន លើការយកបច្ចេកវិទ្យា GAI ទៅប្រើប្រាស់ក្នុងផ្លូវដែលមានប្រយោជន៍ ដើម្បី

ពង្រឹងភាពធន់ក្នុងសង្គមស៊ីវិលប្រឆាំងនឹងការបន្លំព័ត៌មានក្នុងប្រព័ន្ធឌីជីថល និងលើកកម្ពស់គុណភាពនៃលំហព័ត៌មានឌីជីថល។ ជាឧទាហរណ៍ ការបង្កើនការវិនិយោគលើការអភិវឌ្ឍ និងការប្រើប្រាស់វិធីសាស្ត្រនានា ដើម្បីស្វែងរក និងដាក់ស្លាកសម្គាល់លើមាតិកាដែលបង្កើតឡើងដោយបច្ចេកវិទ្យា AI អាចជួយឱ្យបុគ្គលម្នាក់ៗសម្គាល់មាតិកាសំយោគបានកាន់តែច្បាស់លាស់។ បច្ចេកវិទ្យា GAI ក៏អាចគាំទ្រដល់ការដេញដោលស៊ីវិលតាមប្រព័ន្ធអនឡាញឱ្យមានគុណភាពខ្ពស់ជាងមុនផងដែរ ដោយការផ្ដល់ដំណឹងព្រមានដល់អ្នកប្រើប្រាស់ នៅពេលដែលពួកគេប្រើប្រាស់ភាសាប្រកបដោយការគុំកួន និងញុះញង់។

## VI. សេចក្ដីសន្និដ្ឋាន

ការរីករាលដាលនៃព័ត៌មានក្នុងទម្រង់ Information Disorder គឺជាបញ្ហាប្រឈមដ៏សំខាន់បំផុតមួយនៃយុគសម័យឌីជីថល ដែលប៉ះពាល់ដល់ការវិនិច្ឆ័យរបស់បុគ្គល, ទំនុកចិត្តសង្គម, ដំណើរការប្រជាធិបតេយ្យ និងសន្តិសុខជាតិ។ ប៉ុន្តែ វិបត្តិនេះមិនមែនជាបញ្ហាដែលគ្មានដំណោះស្រាយឡើយ ដោយក្នុងនោះ តាមរយៈការសិក្សាពីបទពិសោធអន្តរជាតិ ដូចជា សហរដ្ឋអាមេរិក និងយុទ្ធសាស្ត្រឆ្លើយតបជាក់ស្ដែងរបស់កម្ពុជា យើងអាចរួមគ្នាពង្រឹងភាពធន់នៃប្រព័ន្ធព័ត៌មាន តាមរយៈអក្ខរកម្មព័ត៌មាន, ការជំរុញឱ្យសាធារណជនមានការគិតពិចារណាបែបស៊ីជម្រៅ, ការចេះផ្ទៀងផ្ទាត់ប្រភព និងការគ្រប់គ្រងថ្នាលឌីជីថលប្រកបដោយការទទួលខុសត្រូវជាដើម។ ដូច្នេះ នៅក្នុងយុគសម័យដែលពលរដ្ឋគ្រប់រូបសុទ្ធតែអាចបង្កើត និងចែកចាយមាតិកាបាន ការបណ្ដុះវប្បធម៌នៃការទទួលខុសត្រូវ និងការធ្វើជាពលរដ្ឋឌីជីថលដ៏ឆ្លាតវៃ លែងជាជម្រើសទៀតហើយ តែជាគ្រឹះដ៏សំខាន់សម្រាប់ស្ថិរភាព និងវឌ្ឍនភាពសង្គម។ មានតែការរួមគ្នាប្រុងប្រយ័ត្ន និងការអប់រំជាប្រចាំប៉ុណ្ណោះ ទើបជាខែលការពារដ៏រឹងមាំបំផុតសម្រាប់មនុស្សគ្រប់រូប ប្រឆាំងនឹងការបំពុលពីព័ត៌មាននានាក្នុងទម្រង់ Information Disorder៕

## ឯកសារយោង


- *Information disorder: disinformation, misinformation and a 'polluted' information space, February 2026, Parliament of Australia*, ចូលអានថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦
- *Information disorder: The essential glossary*, ចេញផ្សាយថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨, ចូលអានថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/2s3pz9mp
- *Cognitive manipulation and AI will shape disinformation in 2026. Here's how to build resilience*, ចេញផ្សាយថ្ងៃទី១២ ខែមិនា ឆ្នាំ២០២៦, ចូលអានថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/yc28wcz8
- *Information Disorder: Toward an interdisciplinary framework for research and policymaking*, ចេញផ្សាយថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧, ចូលអានថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/4zpu3per
- *What motivates individuals to disseminate disinformation on social media platforms? A study based on the SOR framework*, ចូលអានថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/2uspks3m
- *Epidemic modeling for misinformation spread in digital networks through a social intelligence approach*, ចេញផ្សាយថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៤, ចូលអានថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/2fccf37a
- *The history of misinformation and disinformation*, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/msnuaakm
- *Journalism, 'Fake News' & Disinformation. UNESCO Series*, ចេញផ្សាយឆ្នាំ២០១៨, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦
- *Examining the association between social media fatigue, cognitive ability, narcissism and misinformation sharing*, ចេញផ្សាយថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/4ttsz3r6
- *The issues caused by misinformation—How workers and organizations deal with it*, ចេញផ្សាយថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/42re3dxe
- *The Polarizing Impact of Political Disinformation and Hate Speech*, ចេញផ្សាយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/3xetxbrh
- *Information disorder: disinformation, misinformation and a 'polluted' information space*, ចេញផ្សាយខែកុម្ភៈ ឆ្នាំ២០២៦, ចូលអានថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/nmepazhz
- *Disinformation: 10 steps to protect yourself and others*, ចេញផ្សាយថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥, ចូលអានថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/2mcuects
- *6 tips to spot and stop information manipulation*, ចូលអានថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦, https://ec.europa.eu/stories/6-tips/

- A quick guide to spotting misinformation, ចេញផ្សាយថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៥, ចូលអានថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/br75rnad
- How to spot fake news, ចេញផ្សាយថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៥, ចូលអានថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/5n7ra43s
- Democratic Roadmap: Building Civic Resilience to the Global Digital Information Manipulation Challenge, ចេញផ្សាយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤, ចូលអានថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦, https://2021-2025.state.gov/roadmap-info-integrity/
- A short guide to the history of ′fake news′ and disinformation, ចូលអានថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/25tv8mue
- Tracking Information Disorder, ចេញផ្សាយឆ្នាំ២០២១, ចូលអានថ្ងៃទី២២ ខែមិថុនាឆ្នាំ២០២៦, https://tinyurl.com/59z559r4
- Infodemic, ចូលអានថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/4d3zhjwp
- Journalism, ‵Fake News′ and Disinformation: A Handbook for Journalism Education and Training, ចេញផ្សាយថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/ucbpvv5c
- Information Disorder: Lessons from Australia, ចេញផ្សាយឆ្នាំ២០២២, ចូលអានថ្ងៃទី២៤ ខែមិថុនាឆ្នាំ២០២៦, https://tinyurl.com/yxw3se7m
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចេញផ្សាយថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦
- ក្រសួង កំពុងរៀបចំច្បាប់ថ្មីស្តីពីរបបសារព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងសម័យឌីជីថល, ចេញផ្សាយថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/4rcm962a
- សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ, ចេញផ្សាយថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦
- ប្រកាស ស្តីពី ការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន, ចេញផ្សាយថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦
- ផែនការសកម្មភាពស្តីពីការកសាងនិងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ឆ្នាំ២០២៥-២០២៨, ចេញផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦
- សេចក្តីប្រកាសព័ត៌មាន ស្តីពី លទ្ធផលនៃវេទិកាពិភាក្សាមហាអនុតំបន់មេគង្គ សម្រាប់យុទ្ធនាការលុបបំបាត់ព័ត៌មានក្លែងក្លាយ, ចេញផ្សាយថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៦, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦
- ក្រសួងព័ត៌មាន គ្រោងបើកយុទ្ធនាការ «និយាយថាទេចំពោះព័ត៌មានក្លែងក្លាយ- Say No to FakeNews», ចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦, https://tinyurl.com/2xcrzjdv

- *ក្រសួងព័ត៌មាន ប្រកាសបើកយុទ្ធនាការ «និយាយថាទេចំពោះព័ត៌មានក្លែងក្លាយ»ជំហាន ២, ចេញផ្សាយថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦,* https://tinyurl.com/4p5nadud
- *របាយការណ៍ស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា, ចេញផ្សាយខែមេសា ឆ្នាំ២០២៦, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦*
- *ឆ្នាំ២០២៥ ក្រសួងរកឃើញព័ត៌មានក្លែងក្លាយជិតបួនពាន់ករណី ភាគច្រើនពាក់ព័ន្ធនឹងជម្លោះព្រំដែនកម្ពុជា-ថៃ, ចេញផ្សាយថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦,* https://tinyurl.com/mtntuvry
- *Digital 2026: Cambodia, ចេញផ្សាយថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០២៥, ចូលអានថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦,* https://tinyurl.com/3x64trb4


---

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

កម្ពុជា ៤.0 Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center